**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚ ❈ ៚

តុលាការខេត្ត ព្រះវិហារ

សាលក្រម

លេខ០៩ ចុះថ្ងៃទី ១៦

ខែ៩ ឆ្នាំ ២០០៤

រឿងរដ្ឋប្បវេណី

លេខ៦១ ចុះថ្ងៃទី ២០

ខែ១០ ឆ្នាំ ២០០៣

# តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការខេត្តព្រះវិហារ

**បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្ត**

ព្រះវិហារ នាថ្ងៃទី ១៦ ខែ ០៩ ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

ចៅក្រមជំនុំជំរះ

លោក[redacted] អនុប្រធានតុលាការខេត្ត

តំណាងអយ្យការ

លោក[redacted] ព្រះរាជអាជ្ញាអមតុលាការខេត្ត

ក្រឡាបញ្ជី

លោកស្រី [redacted]

ដើម្បីជំនុំជំរះរឿងក្តីរដ្ឋប្បវេណីលេខ ៦១ ចុះថ្ងៃទី ២០ ខែ ១០ ឆ្នាំ២០០៣ ដែលមានកម្មវត្ថុបណ្តឹង :

(កូនបំណុល) សុំមោឃៈភាពនៃកិច្ចសន្យា ចុះថ្ងៃទី១៣ ខែ៧ ឆ្នាំ២០០០

(ម្ចាស់បំណុល) សុំអោយអនុវត្តកិច្ចសន្យា ចុះថ្ងៃទី១៣ ខែ៧ ឆ្នាំ២០០០

រវាងដើមចោទឈ្មោះ [redacted] វន្ថា (កូនបំណុល) ភេទប្រុស អាយុ៤៣ឆ្នាំ របររកស៊ីលក់ដូរ ទីលំនៅសព្វថ្ងៃនៅភូមិ អណ្តូងពោធិ ឃុំកំពង់ប្រណាក ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ។ ឪពុកឈ្មោះ [redacted] ទ្រី (ស្លាប់) ម្តាយឈ្មោះ [redacted] ហេង (រស់) ប្រពន្ធឈ្មោះ [redacted] ថាវី មានកូន៥នាក់ មានមេធាវីឈ្មោះ [redacted] កែវស៊ីវិន (អវត្តមាន) ជាអ្នកការពារ ។

និងចុងចំលើយឈ្មោះ [redacted] ឈីម ម្ចាស់បណ្តឹងសារត្រឡប់ (ម្ចាស់បំណុល) ភេទប្រុស អាយុ ៥៦ឆ្នាំ របររកស៊ីលក់ដូរ ទីលំនៅសព្វថ្ងៃនៅភូមិកណ្តាល ឃុំកំពង់ប្រណាក ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ។ ឪពុកឈ្មោះ[redacted]នូវ (ស្លាប់) ម្តាយឈ្មោះ[redacted] អ៊ី (ស្លាប់) ប្រពន្ធឈ្មោះ [redacted] ឆូច មានកូន ២នាក់ មេធាវី គ្មាន ។

**ឯរឿងហេតុមានដូចតទៅ :**

-តាមពាក្យបណ្តឹងចុះថ្ងៃទី១៦ ខែ១០ ឆ្នាំ២០០៣ របស់ឈ្មោះ [redacted] វន្ថា បានប្តឹងសុំមោឃៈកិច្ចសន្យា ចុះថ្ងៃទី ១៣ ខែ ៧ ឆ្នាំ២០០០ រវាងខ្លួននិងឈ្មោះ [redacted] ឈីម ដោយហេតុថាខ្លួនទីទ័លពេក ខ្លួនធ្វើដោយ មិនយល់ដោយមានការភ័ន្តច្រឡំ និងត្រូវទទួលការគំរាម បំភិតបំភ័យពីលោក [redacted] ឈីម ធ្វើអោយខ្លួនបង្ខំចិត្តផ្តិតមេដៃលើកិច្ចសន្យា ចុះថ្ងៃទី១៣ ខែ ៧ ឆ្នាំ២០០០ ដែលមានទឹកប្រាក់ចំនួន ៧០៨៦ ដុល្លាអាមេរិក ដោយខ្លួនបានទទួលប្រាក់

សុទ្ធចំនួន ៣៩០០ ដុល្លាអាមេរិក ពីឈ្មោះ [redacted] ឈឹម ហើយខ្លួនបានបង់ការប្រាក់ជូនឈ្មោះ [redacted] ឈឹម ចំនួន២៧ខែ ស្មើរ ៤២២១.៧២ ដុល្លាអាមេរិក ។

-ពាក្យបណ្តឹងសារត្រឡប់ ចុះថ្ងៃទី២០ ខែ១០ ឆ្នាំ២០០៣ឈ្មោះ ម៉ាន់ ឈឹម ប្តឹងសុំអោយឈ្មោះ [redacted] វណ្ណា អនុវត្តន៏កិច្ចសន្យា ចុះថ្ងៃទី១៣ ខែ៧ ឆ្នាំ២០០០ រវាងខ្លួន និង [redacted] វណ្ណា ដោយសំអាងហេតុថា នៅថ្ងៃទី១៣ ខែ៧ ឆ្នាំ២០០០ ឈ្មោះ [redacted] វណ្ណា បានចុះកិច្ចសន្យាខ្ចីចងការខ្លួនសរុបទាំងអស់ ៧០៨៦ ដុល្លាអាមេរិក បូករួមទាំងប្រាក់ជំពាក់ថ្លៃទំនិញ ៣៩០ ដុល្លាផងដែរ ដោយបានគិតការប្រាក់ ៣% ក្នុង ១ខែ ហើយបានដាក់បញ្ចាំប័ណ្ណសំគាល់សិទ្ធិ លេខ ៣ហ០០០០៦២ ចុះថ្ងៃទី១ ខែ១២ ឆ្នាំ១៩៩៩ ដោយបញ្ជាក់ថា ដាក់ដីទំហំ ១០.៥០ម x ៣៨ម កន្លងមក [redacted] វណ្ណា មិនអនុវត្តកិច្ចសន្យាទេ ។ ដូច្នេះខ្លួនសុំអោយ [redacted] វណ្ណា អនុវត្តកិច្ចសន្យានិងទារជំងឺចិត្ត ៤០០០ដុល្លា សំរាប់ជួសជុលការខូចខាតផលប្រយោជន៍របស់ខ្លួន ។

**នាពេលសវនាការ**

-ដើមចោទឈ្មោះ [redacted] វណ្ណា (កូនបំណុលអវត្តមាន)

-ក្រឡាបញ្ជីអានកំណត់ហេតុយកចំលើយ របស់ដើមចោទ ឈ្មោះ [redacted] វណ្ណា ចុះថ្ងៃទី២៨ ខែ០១ ឆ្នាំ២០០៤

-ម្ចាស់បណ្តឹងសារត្រឡប់ ឈ្មោះ [redacted] ឈឹម (ម្ចាស់បំណុល) បានឆ្លើយថាខ្លួនប្តឹងសុំអោយដើមចោទ ឈ្មោះ [redacted] វណ្ណា (កូនបំណុល) អនុវត្តកិច្ចសន្យា ចុះថ្ងៃទី១៣ ខែ៧ ឆ្នាំ២០០០ មានទឹកប្រាក់ចំនួន ៧០៨៦ដុល្លាអាមេរិក ។ ដោយសំអាងហេតុថា កាលពីឆ្នាំ១៩៩៩ ឈ្មោះ [redacted] វណ្ណា បានខ្ចីចងការខ្លួនចំនួន ៣៧១២ដុល្លាអាមេរិក ដោយព្រមព្រៀងគិតការប្រាក់ ៤% ក្នុង ១ខែ តែឈ្មោះ [redacted] វណ្ណា មិនបានសងខ្លួនទាល់តែសោះ ហើយជំពាក់ការប្រាក់ខ្លួនចំនួន១០ខែ ស្មើ ១៤៨៤ ដុល្លាអាមេរិក នៅថ្ងៃទី២៦ ខែ៦ ឆ្នាំ២០០០ ខ្លួនបានប្តឹងមកតុលាការខេត្ត ក្រោយមកតុលាការបានធ្វើការសំរុះសំរួល ហើយឈ្មោះ [redacted] វណ្ណា ទទួលស្គាល់ថាបានជំពាក់ប្រាក់ខ្លួនតាមចំនួនដែលបានប្តឹងទាមទារមែន ហើយសុំខ្ចីបន្ថែម១៥០០ ដុល្លាអាមេរិក ទៀតដោយសុខចិត្តបញ្ចាំប្លង់ដីមកអោយខ្លួនដោយព្រមព្រៀងគ្នា គិតការប្រាក់ ៣%ក្នុង ១ខែ លើប្រាក់ ៥២១២ដុល្លាអាមេរិក ឯប្រាក់ជំពាក់ថ្លៃទំនិញ៣៩០ដុល្លាអាមេរិក និង ប្រាក់ការជំពាក់១៤៨៤ ដុល្លាអាមេរិក មិនបានគិតការប្រាក់ទេ សរុបទាំងអស់ ៧០៨៦ ដុល្លាអាមេរិក ហើយបានធ្វើកិច្ចសន្យាថ្មីមួយ ចុះថ្ងៃទី១៣ ខែ៧ ឆ្នាំ២០០០ ដោយស្ម័គ្រចិត្តទាំងសងភាគី ដោយគ្មានការគំរាមឬបំភិតបំភ័យឡើយ ។ កន្លងមក [redacted] វណ្ណា បានអនុវត្តកិច្ចសន្យាបាន ៣ឆ្នាំ ៣ខែ ២ថ្ងៃ ហើយបានបង់ការប្រាក់អោយខ្លួនបានចំនួន២៧ខែមកហើយ ស្រាប់តែនៅខែ១០ ឆ្នាំ២០០៣ (កូនបំណុល) បានប្តឹងសុំមោឃៈភាពនៃកិច្ចសន្យា ចុះថ្ងៃទី១៣ ខែ៧ ឆ្នាំ២០០០ទៅវិញ ។

តំណាងអយ្យការសន្និដ្ឋានថា សូមតុលាការពិចារណាសំរេចទៅតាមច្បាប់ ។

-បានពិនិត្យលើអវត្តមានរបស់ដើមចោទ (កូនបំណុល)

-បានស្តាប់ក្រឡាបញ្ជីអានកំណត់ហេតុយកចម្លើយរបស់ដើមចោទ

-បានស្តាប់ចម្លើយម្ចាស់បណ្តឹងសារត្រឡប់

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ



Scanned with CamScanner

## តុលាការ

### ក្រោយពីការពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

យល់ឃើញថា:    ពាក្យបណ្តឹងចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៣ របស់ដើមចោទឈ្មោះ [redacted] វិន្ទា ( កូនបំណុល ) មានលក្ខណៈត្រឹមត្រូវតាមទំរង់តែផ្ទុយពីគតិច្បាប់ ។

យល់ឃើញថា: ពាក្យបណ្តឹងសារគ្រឡប់ចុះថ្ងៃទី២០ ខែ តុលា ឆ្នាំ២០០៣ របស់ឈ្មោះ [redacted] ឈឹម មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

យល់ឃើញថា:    ផ្អែកតាមកំណត់ហេតុផ្សះផ្សា ចុះថ្ងៃទី១៣ ខែ៧ ឆ្នាំ២០០០ ឈ្មោះ [redacted] ឈឹម បានប្តឹងទារប្រាក់ពីឈ្មោះ [redacted] វិន្ទា ( កូនបំណុល ) ហើយតុលាការបានកោះហៅមកផ្សះផ្សាដោយ ( កូនបំណុល ) [redacted] វិន្ទា ទទួលស្គាល់ទឹកប្រាក់ ៣៧១២ដុល្លា និងការប្រាក់១៨៨៤ដុល្លា ប្រាក់ជំពាក់ថ្លៃទំនិញ៣៩០ដុល្លា ហើយគូភាគីបានព្រមព្រៀងគ្នាធ្វើកិច្ចសន្យាមួយដោយបញ្ចាំប្លង់ដីលេខ ០០០០៦២ ចុះថ្ងៃទី១ ខែ១២ ឆ្នាំ១៩៩៩ ពាក់កណ្តាលហើយ ម្ចាស់បំណុលបានបន្ថែមប្រាក់ចំនួន ១៥០០ ដុល្លា ( អោយកូនបំណុល ) ទៀតលើប្រាក់៣៧១២ ដុល្លាអាមេរិក ស្មើនិង ៥២១២ ដុល្លា បូកបញ្ចូលការប្រាក់ជំពាក់ចំនួន ១៨៨៤ ដុល្លា និង ថ្លៃទំនិញ៣៩០ ដុល្លា សរុបស្មើនិង៧០៨៦ ដុល្លាអាមេរិក ហើយគិតការប្រាក់ ៣% ក្នុង ១ខែ លើប្រាក់៥២១២ ដុល្លាអាមេរិកប៉ុណ្ណោះ ដោយមានកិច្ចចុះថ្ងៃទី១៣ ខែ៧ ឆ្នាំ២០០០ ហើយម្ចាស់បំណុលបានសំណូមពរអោយកូនបំណុលមកបង់ការប្រាក់នៅតុលាការ ដើម្បីជៀសវាងមានបញ្ហាទៅថ្ងៃក្រោយ កូនបំណុលឈ្មោះ [redacted] វិន្ទា ក៏បានព្រមព្រៀងដោយស្ម័គ្រចិត្តគ្មានការបង្ខិតបង្ខំ ផងនោះមានលក្ខណៈសមស្របតាមច្បាប់ ។

យល់ឃើញថា:    កិច្ចសន្យាចុះថ្ងៃទី១៣ ខែ៧ ឆ្នាំ២០០០ រវាងឈ្មោះ ទ្រី វិន្ទា ( កូនបំណុល ) និងឈ្មោះ [redacted] ឈឹម ( ម្ចាស់បំណុល ) កើតឡើងដោយការព្រមព្រៀងទ្វារភាគី មានលក្ខណៈសមស្របតាមច្បាប់ ។

យល់ឃើញថា:    ដើមចោទឈ្មោះ [redacted] វិន្ទា ( កូនបំណុល ) បានអនុវត្តកិច្ចសន្យាបានរយៈពេល ៣ឆ្នាំ ៣ខែ ២ថ្ងៃ ( គិតមកដល់ថ្ងៃដាក់ពាក្យប្តឹង ) ហើយបានបង់ការប្រាក់អោយម្ចាស់បំណុលបាន ២៧ខែ បែរជាមកប្តឹងសុំមោឃៈភាពនៃកិច្ចសន្យា ដោយមូលហេតុថា មានការភ័ន្តច្រឡំ ម្ចាស់បំណុលបំភិតបំភ័យ គំរាម គ្មានមូលដ្ឋានច្បាស់លាស់មិនគួរអោយជឿបាន ។

យល់ឃើញថា:    ដើមចោទឈ្មោះ [redacted] វិន្ទា ( កូនបំណុល ) បដិសេធថាខ្លួនមិនទទួលស្គាល់ប្រាក់ចំនួន ៧០៨៦ដុល្លា ដោយខ្លួនទទួលស្គាល់ប្រាក់ ចំនួន៣៥០០ដុល្លា គ្មានសំអាងអ្វីច្បាស់លាស់ តុលាការមិនគួរជឿបាន ។

យល់ឃើញថា:    ម្ចាស់បណ្តឹងសារគ្រឡប់ [redacted] ឈឹម ( ម្ចាស់បំណុល ) បានបញ្ជាក់ថាកិច្ចសន្យាចុះថ្ងៃទី១៣ ខែ៧ ឆ្នាំ២០០០ ធ្វើឡើងដោយមានការព្រមព្រៀងពីភាគីកូនបំណុល ដោយខ្លួនមិនបានគំរាមឬ បង្ខិតបង្ខំកូនបំណុលឡើយ ហើយកូនបំណុល បានស្ម័គ្រចិត្តផ្តិតមេដៃដោយទ្វេរភាគី មានទឹកប្រាក់សរុប ៧០៨៦ដុល្លា មានមូលដ្ឋានច្បាស់លាស់គួរអោយតុលាការជឿបាន ។

យល់ឃើញថា: ម្ចាស់បណ្តឹងសារត្រឡប់ [redacted] ឈឹម (ម្ចាស់បំណុល) ប្តឹងទារប្រាក់ជំងឺចិត្ត៤០០០ដុល្លា សំរាប់ជួសជុលការខូចខាតផលប្រយោជន៍របស់ខ្លួនយូរឆ្នាំ មានលក្ខណៈសមស្របតាមច្បាប់ ។

យល់ឃើញថា: ម្ចាស់បណ្តឹងសារត្រឡប់ [redacted] ឈឹម (ម្ចាស់បំណុល) ប្តឹងសុំអោយកូនបំណុលអនុវត្តកិច្ចសន្យា ដោយសងប្រាក់ខ្លួនចំនួន៧០៨៦ ដុល្លាអាមេរិក បើគ្មានប្រាក់សងទេ សុំអោយរឹបអូសដី ទំហំ ១០,៥០ម x ៣៨ម ប៉ែកខាងលិចតាមប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនៈវត្ថុលេខ ០០០០៦២ ចុះថ្ងៃទី១ ខែ១២ ឆ្នាំ១៩៩៩ និងប្តឹងសុំអោយ ដាក់គុកបង្ខំរូបកាយ កូនបំណុល មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

យល់ឃើញថា: ដើមចោទឈ្មោះ [redacted] វន្ថា (កូនបំណុល) មិនព្រមទទួលដីកាអញ្ជើញសវនាការចំនួន ២លើកមកហើយ ដោយបានអានហើយប្រកែកមិនព្រមទទួល ។

យល់ឃើញថា: មេធាវីការពារកូនក្តីអោយឈ្មោះ [redacted] វន្ថា បានទទួលលិខិតអញ្ជើញត្រឹមត្រូវហើយ តែសាមីខ្លួនមិនព្រមចូលមកក្នុងពេលសវនាការឡើយ ។

-តាមក្រិតលេខ ០៧ក្រ ចុះថ្ងៃទី ០៨ ខែ០៣ ឆ្នាំ១៩៩៣ ប្រកាស់អោយប្រើច្បាប់ ស្តីពីប្រាក់ប្រដាប់ក្តីនោះពន្ធសមាមាត្រត្រូវគិត ១% លើប្រាក់ដែលតុលាការបានសំរេច ។

ហេតុដូច្នេះតុលាការខេត្តព្រះវិហារ

វិនិច្ឆ័យសេចក្តី :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី ១៦ ខែ១០ ឆ្នាំ២០០៣ របស់ឈ្មោះ [redacted] វន្ថា (កូនបំណុល) ទុកជាត្រឹមត្រូវតាមទំរង់ តែបដិសេធចោលដោយផ្ទុយពីគតិច្បាប់ ។ តាមមាត្រាទី១៩ នៃច្បាប់ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

២-ទទួលបណ្តឹងសារត្រឡប់ចុះថ្ងៃទី២០ ខែ១០ ឆ្នាំ២០០៣ របស់ឈ្មោះ [redacted] ឈឹម (ម្ចាស់បំណុល) ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣-បង្គាប់អោយឈ្មោះ [redacted] វន្ថា (កូនបំណុល) សងប្រាក់ចំនួន៧០៨៦ ដុល្លាអាមេរិក (ប្រាំពីរពាន់ប៉ែតសិប ប្រាំមួយដុល្លាអាមេរិក) អោយឈ្មោះ [redacted] ឈឹម បើគ្មានប្រាក់សងត្រូវរឹមអូសដី ទំហំ ១០,៥០ម x ៣៨ម ប៉ែកខាងលិចតាមប័ណ្ណសំគាល់សិទ្ធកាន់កាប់អចលនៈវត្ថុលេខ ០០០០៦២ ចុះថ្ងៃទី០១ ខែ១២ ឆ្នាំ១៩៩៩ មានព្រំប្រទល់ខាងកើត ជាប់ប៉ែកខាងកើតនៃប្លង់ ខាងលិចជាប់ដី [redacted] ហូ ខាងជើងជាប់ផ្លូវ ខាងត្បូងជាប់ដី [redacted] សំអាត ស្ថិតនៅភូមិអណ្តូងពោធិ ឃុំកំពង់ប្រណាក ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ លក់ឡាយឡុងដើម្បីធានាសំណង ។ ក្នុងករណីរឹងរូស ត្រូវដាក់គុកបង្ខំលើរូបការតាមច្បាប់ ស្តីពីនីតិវិធីអនុវត្តសាសក្រម រដ្ឋប្បវេណី ។

៤-បង្គាប់អោយឈ្មោះ [redacted] វន្ថា បង់ប្រាក់ជំងឺចិត្ត អោយឈ្មោះ [redacted] ឈឹម ចំនួន ២.០០០ ដុល្លាអាមេរិក ។ ការទាមទារលើសពីនេះលើកចោល ។

៥-ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹង១.៨០០រ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រ កិច្ចការប្រគល់ដីការកោះ៥០០០រ សរុប ៧.០០០រ ប្រាក់នេះបានកាត់យកពីប្រាក់៧.០០០រ ដែលដើមចោទបានបង់រួចហើយ ។ កាលបើហូសបណ្តឹងឧទ្ធរណ៍បង្គាប់អោយបង់ពន្ធសមាមាត្រ ១% លើទឹកប្រាក់ ៧.០៨៦ ដុល្លាអាមេរិច

និង ប្រាក់ជំងឺចិត្ត ២.០០០ ដុលារអាមេរិក សរុប ៩.០៨៦ ដុល្លារអាមេរិកស្មើ ៩០.៨៦ ដុល្លារអាមេរិក ប្រាក់នេះត្រូវបង់ ចូលថវិការរដ្ឋ ៨០% រង្វាន់ក្រឡាបញ្ជី ទូទាំងប្រទេស ២០% ពន្ធសមាមាត្រនេះត្រូវអោយឈ្មោះ [redacted] ឈឹម បង់មុន ទើបបង្គាប់អោយឈ្មោះ [redacted] វិត្ថា សងទៅ ឈ្មោះ ម៉ាន់ ឈឹម ជាក្រោយ ។

៦- សាលក្រមនេះជំនុំជំរះ ប្រកាសជាសាធារណៈ ចំពោះម្ចាស់បណ្តឹង សាត្រឡប់ ឈ្មោះ [redacted] ឈឹម កំបាំងមុខដើមចោទ ឈ្មោះ [redacted] វន្ថា និង មេធាវី ដើមចោទ តែចាត់ទុកជាចំពោះមុខ សំរេចបើកផ្លូវឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

ចៅក្រមជំនុំជំរះ

[redacted]

ក្រឡាបញ្ជី

[redacted]

៤១០

410

Scanned with CamScanner